គណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា
Cooperation Committee for Cambodia
Comité de Coopération Pour le Cambodge



# សេចក្តីព្រាង
# វេទិកាសហគមន៍អ្នកប្រតិបត្តិឧបករណ៍មិនបង្កទំនាស់
# ក្រោមប្រធានបទ "ការបំប្លែងពីគោលការណ៍ ទៅជាការអនុវត្ត"

**កាលបរិច្ឆេទ៖ ថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០២៦ (៨:០០ព្រឹក-៤:៣០ រសៀល)**

**ទីកន្លែង៖ រាជធានីភ្នំពេញ (ទីតាំងជាក់លាក់នឹងជម្រាបជូនពេលក្រោយ)**

## ១.សាវតា

គណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា (គ.ស.ក) គឺជាអង្គការសមាជិកភាពឈានមុខគេ ដែលមានសមាជិកជាអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក និងបរទេសនៅក្នុងប្រទេសកម្ពុជា។ គ.ស.ក បានបង្កើត និងអនុវត្តកម្មវិធីគ្រប់គ្រងអភិបាលកិច្ច (GHP) ២០២៤-២០២៨ ដើម្បីរួមចំណែកពង្រឹងអង្គការសង្គមស៊ីវិល ដោយផ្តល់ឱ្យពួកគេនូវបរិយាកាសអំណោយផល និងលំហរប្រជាធិបតេយ្យកាន់តែប្រសើរ ចូលរួមដោះស្រាយបញ្ហាប្រឈមក្នុងការអភិវឌ្ឍន៍នៅកម្ពុជា។ តាមរយៈវិធីសាស្រ្តការងាររបស់ខ្លួន គ.ស.ក លើកទឹកចិត្តដល់ការរួមបញ្ចូលឧបករណ៍មិនបង្កទំនាស់ (Do No Harm- DNH) និងវិធីសាស្រ្តផ្អែកលើសិទ្ធិ (RBA) ទៅក្នុងស្ថាប័ន និងគម្រោងកម្មវិធីរបស់ដៃគូ និងសមាជិករបស់ខ្លួន។ វិធីសាស្រ្តនេះ សង្កត់ធ្ងន់ទៅលើការកាត់បន្ថយឲ្យបានអប្បបរមានូវផលវិបាកជាអវិជ្ជមានដែលមិនបានរំពឹងទុក និងការបង្កើនផលជះជាវិជ្ជមាននៅក្នុងសកម្មភាពនៃកម្មវិធី ឬគម្រោង។ សកម្មភាពជាបន្តបន្ទាប់ត្រូវបានបង្កើតឡើង និងលើកកម្ពស់ចំណេះដឹង និងសមត្ថភាពសម្រាប់អង្គការសង្គមស៊ីវិលទៅលើ DNH ដែលរួមមាន សិក្ខាសាលាផ្សព្វផ្សាយ សិក្ខាសាលាស្តីពីការអនុវត្ត ការបង្វឹក ការរៀនសូត្រនិងការចែករំលែកការអនុវត្តតាមរយៈវេទិកាសហគមន៍នៃអ្នកប្រតិបត្តិជាដើម។

ឧបករណ៍មិនបង្ករទំនាស់ (Do No Harm - DNH) បានក្លាយជាគោលការណ៍ដ៏សំខាន់សម្រាប់អង្គការ និងអ្នកអនុវត្តការងារក្នុងវិស័យមនុស្សធម៌ អភិវឌ្ឍន៍ សុខភាពសាធារណៈ សន្តិភាព និងការពង្រឹងសហគមន៍ នាពេលបច្ចុប្បន្ន។ ទោះបីជាគោលការណ៍ Do No Harm ត្រូវបានទទួលស្គាល់ និងយល់ដឹងយ៉ាងទូលំទូលាយក៏ដោយ ក៏អ្នកអនុវត្តជាច្រើននៅតែប្រឈមនឹងបញ្ហាក្នុងការបកប្រែគោលការណ៍ទាំងនេះទៅជាសកម្មភាពជាក់ស្តែងនៅក្នុងការរៀបចំ ការអនុវត្ត ការតាមដាន និងការកែសម្រួលកម្មវិធី។ ភាពស្មុគស្មាញនៃទំនាក់ទំនងសង្គម បរិបទនយោបាយ កត្តាអំណាច និងភាពបន្ទាន់នៃប្រតិបត្តិការងារ អាចធ្វើឱ្យការអនុវត្ត Do No Harm មានភាពប្រឈម។

ដូច្នេះវេទិកាសហគមន៍អ្នកប្រតិបត្តិឧបករណ៍មិនបង្ករទំនាស់ (DNH) គឺជាសកម្មភាពមួយក្នុងចំណោមសកម្មភាពផ្សេងទៀត ដែលរៀបចំពីរដងក្នុងមួយឆ្នាំ ដើម្បីផ្តល់ឱកាសសម្រាប់ការចែករំលែកបទពិសោធន៍ កសាងបណ្តាញ ការកែលម្អជាបន្តបន្ទាប់ និងការច្នៃប្រឌិតក្នុងចំណោមអ្នកអនុវត្តDNH។ វេទិកាលើកទី១នៅឆ្នាំ២០២៦នេះ នឹងគ្រោងរៀបចំឡើងនៅថ្ងៃទី២៦ ខែសីហា ឆ្នាំ២០២៦ ហើយ រំពឹងថានឹងមាន



www.ccc-cambodia.org
info@ccc-cambodia.org
T +855 (0)23 214 152
F +855 (0)23 216 009

#9-11, Street 476,
Toul Tompoung 1, Chamkamorn
P.O. Box 885, Phnom Penh,
Cambodia

Accountability គណនេយ្យភាព
GPP
23/02/2023 22/02/2028
Symbol of Trust

អ្នកចូលរួមចំនួន ៤០-៥០ នាក់ ដើម្បីមានឱកាសជួបជុំគ្នា និងចែករំលែកបទពិសោធន៍ ការសិក្សារៀនសូត្រពីគ្នាទៅវិញទៅមក និងពង្រឹងសមត្ថភាពក្នុងការអនុវត្តគោលការណ៍DNH ឲ្យកាន់តែមានប្រសិទ្ធិភាព។

## ២.គោលបំណង

- **ដើម្បីសិក្សាស្វែងយល់អំពីវិធីសាស្រ្តជាក់ស្តែង**ក្នុងការបញ្ចូលគោលការណ៍ DNH នៅគ្រប់ដំណាក់កាលនៃវដ្តគម្រោង
- **ចែករម្លែកអំពីឧទាហរណ៍ជាក់ស្តែង ករណីសិក្សា និងវិធីសាស្រ្តនានា**ដែលគាំទ្រដល់ការអនុវត្តកម្មវិធីក្នុងន័យកាត់បន្ថយឲ្យបានអប្បបរមានូវផលវិបាកជាអវិជ្ជមានដែលមិនបានរំពឹងទុក និងការបង្កើនផលជះជាវិជ្ជមាននៅក្នុងសកម្មភាពនៃកម្មវិធី ឬគម្រោង
- **ដើម្បីឆ្លុះបញ្ចាំង បង្កើតនូវជម្រើសអន្តរាគមន៍**ដែលធ្វើឲ្យការអនុវត្តគម្រោង/កម្មវិធីរបស់យើងកាន់តែប្រសើរជាងមុន និង**ពង្រឹងបណ្តាញសហគមន៍អនុវត្តន៍** និងជំរុញការរៀនសូត្របន្តក្រោយវេទិកា។

## ៣.សមាសភាពអ្នកចូលរួម

- តំណាងបុគ្គលិក ០២ នាក់ក្នុងមួយស្ថាប័ន ចំពោះស្ថាប័នដែលធ្លាប់បានចូលរួមសិក្ខាសាលាDNH យ៉ាងតិច០១វគ្គ (DNH exposure workshop)
- បុគ្គលដែលបានចូលរួមក្នុងសិក្ខាសាលាផ្សព្វផ្សាយ DNH និងអនុវត្តគោលគំនិត/ប្រើប្រាស់ឧបករណ៍
- សមាជិកនៃក្រុម Do No Harm Cambodia Team (DNHC-T)
- ឬអ្នកដែលចាប់អារម្មណ៍ចូលរួមចែករំលែកទាក់ទងប្រធានបទ។

## ៤.ការរៀបចំ និងភស្តុភារ

- ការចូលរួមវេទិកានេះ គឺមិនគិតថ្លៃទេ
- អាហារថ្ងៃត្រង់ អាហារសម្រន់ និងសម្ភារ:នឹងត្រូវបានផ្តល់ជូនដោយអង្គការ គ.ស.ក
- ថ្លៃធ្វើដំណើរ ការស្នាក់នៅ និងកន្លែងស្នាក់នៅ នឹងត្រូវរ៉ាប់រងដោយអង្គការសាម៉ីរបស់អ្នកចូលរួមប្រសិនបើអ្នកចូលរួមអញ្ជើញពីតាមបណ្តាញខេត្ត។

## ៥.សេចក្តីព្រាងកម្មវិធី

| ពេលវេលា | សកម្មភាព | អ្នកសម្របសម្រួល/វាគ្មិន |
|---|---|---|
| ៨:០០-៨:៣០ | ការអញ្ជើញមកដល់ និងចុះឈ្មោះ | អង្គការ គសក |
| ៨:៣០-៨:៥០ | មតិស្វាគមន៍ និងណែនាំអំពីកម្មវិធី | តំណាងគណៈគ្រប់គ្រងអង្គការ គសក |
| ៨:៥០-១០:១៥ | **វគ្គទី១៖ រំលឹកអំពីគោលការណ៍នៃឧបករណ៍មិនបង្កគ្រោះថ្នាក់** | ក្រុមការងារបច្ចេកទេសDNHC-T |



www.ccc-cambodia.org
info@ccc-cambodia.org
T +855 (0)23 214 152
F +855 (0)23 216 009
#9-11, Street 476,
Toul Tompoung 1, Chamkamorn
P.O. Box 885, Phnom Penh,
Cambodia

| | | |
|---|---|---|
| | • ជំហ៊ាននៃឧបករណ៍មិនបង្ករទំនាស់<br>• ទំនាក់ទំនងរវាងជំហ៊ាននៃការប្រើប្រាស់ ជាមួយវដ្តនៃការអនុវត្តគម្រោង/កម្មវិធី | |
| ១០:១៥-១០:៣០ | *សម្រាកពិសារអាហារសម្រន់ពេលព្រឹក និងថតរូប* | ក្រុមការងារ គសក (CCC) |
| ១០:៣០-១២:០០ | **វគ្គទី២៖ ចែករំលែកអំពីបទពិសោធន៍ជាក់ស្តែង ក្នុងដំណើរការបញ្ជូលគោលការណ៍DNH ក្នុងការអនុវត្តគម្រោង/កម្មវិធី**<br>• របៀប/វិធីសាស្ត្រដាក់បញ្ចូល និងការអនុវត្ត<br>• បញ្ហាប្រឈម មេរៀន (ឬករណីសិក្សាជាក់ស្តែង) | -ក្រុមការងារបច្ចេកទេសនៃឧបករណ៍មិនបង្ករទំនាស់ (DNHC-T)<br>-តំណាងអង្គការ/ស្ថាប័ន ដែលធ្លាប់បានអនុវត្តDNH |
| ១២:០០-០១:៣០ | *សម្រាកពិសារអាហារថ្ងៃត្រង់* | ក្រុមការងារ គសក (CCC) |
| ០១:៣០-០៣:០០ | **បន្តវគ្គទី២៖ ចែករំលែកអំពីបទពិសោធន៍ជាក់ស្តែង ក្នុងដំណើរការបញ្ជូលគោលការណ៍DNH ក្នុងការអនុវត្តគម្រោង/កម្មវិធី**<br>• ហេតុអ្វីចាំបាច់ត្រូវប្រើប្រាស់/បញ្ជ្រាបគោលការណ៍DNH នៅក្នុងដំណើរការអនុវត្តគម្រោង?<br>• ឬថាតើការប្រើប្រាស់/បញ្ជ្រាបគោលការណ៍DNH នៅក្នុងដំណើរការអនុវត្តគម្រោង បានជួយជម្រុញឲ្យបង្កើនប្រសិទ្ធិភាពនៃការអនុវត្តគម្រោង/កម្មវិធី បានយ៉ាងដូចម្តេច? | -ក្រុមការងារបច្ចេកទេសនៃឧបករណ៍មិនបង្ករទំនាស់ (DNHC-T)<br>-តំណាងអង្គការ/ស្ថាប័ន ដែលធ្លាប់បានអនុវត្តDNH |
| ០៣:០០-០៣:១៥ | *សម្រាកពិសារអាហារសម្រន់* | ទាំងអស់គ្នា |
| ០៣:១៥-០៤:១៥ | **វគ្គទី៣៖ ការរៀបចំជម្រើស និងផែនការបន្ត**<br>• តើសកម្មភាព/ជម្រើសអ្វីខ្លះ ដែលអាចប្រើប្រាស់/បញ្ជ្រាបគោលការណ៍DNH នៅក្នុងដំណើរការអនុវត្តគម្រោងបាន?<br>• ការចងក្រងមេរៀនដែលអាចបន្តយកទៅរៀនសូត្របាន និងអាចបម្លែងពីគោលការណ៍ ទៅជាការអនុវត្ត | -ក្រុមការងារបច្ចេកទេសនៃឧបករណ៍មិនបង្ករទំនាស់ (DNHC-T)<br>-ក្រុមការងារ គសក (CCC) |
| ៤:១៥-៤:៣០ | វាយតម្លៃកម្មវិធី<br>មតិបូកសរុប និងបិទកម្មវិធី | -ក្រុមការងារបច្ចេកទេសនៃឧបករណ៍មិនបង្ករទំនាស់ (DNHC-T) |

**សម្រាប់ព័ត៌មានបន្ថែមសូមទាក់ទង:**
អ្នកស្រី ភោគ ស្រីពេជ្រ (អ្នកឯកទេសពង្រឹងបណ្តាញ)
លេខទំនាក់ទំនង៖ ០៨៩ ៨១ ៨១ ៧៦
សារអេឡិចត្រូនិច៖ sreypich.phok@ccc-cambodia.org

**កំណត់សម្គាល់៖** CCC រក្សាសិទ្ធិក្នុងការផ្លាស់ប្តូររបៀបវារៈ អាស្រ័យលើឧបសគ្គពេលវេលា និងភាពអាចរកបាននៃវាគ្មិន។ CCC នឹងបង្ហោះឯកសារ រូបថត និងសកម្មភាព និងគំនិតសំខាន់ៗ នៅក្នុងគេហទំព័រ CCC និងប្រព័ន្ធផ្សព្វផ្សាយសង្គមសម្រាប់ការចូលប្រើជាសាធារណៈ។